WWF for a living planet®

**WWF-Cambodia**

21, Street 322,
Boeung Keng Kang I,
Phnom Penh, Cambodia

P.O. Box: 2467
Tel: +855 23 218 034
Fax: +855 23 211 909

www.cambodia.panda.org

| **Press Release** | **For immediate release** |
|---|---|

# ចំនួនសត្វផ្សោតទន្លេមេគង្គដែលកំពុងទទួលរងគ្រោះថ្នាក់ជិតផុតពូជ បានកើនឡើងជាលើកដំបូងបំផុត

ភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨៖ បន្ទាប់ពីការធ្លាក់ចុះយ៉ាងធ្ងន់ធ្ងន់នៃចំនួនសត្វផ្សោតទន្លេមេគង្គអស់រយៈពេលរាប់ទសវត្សរ៍ លទ្ធផលនៃការសិក្សាស្រាវជ្រាវដែលធ្វើឡើងរួមគ្នាដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការ WWF-កម្ពុជា ដែលបានចេញផ្សាយនៅថ្ងៃនេះ បានបង្ហាញថា ចំនួនសត្វផ្សោតទន្លេមេគង្គដែលកំពុងទទួលរងគ្រោះថ្នាក់ជិតផុតពូជ បានកើនឡើងពី ៨០ ទៅ ៩២ ក្បាល ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ហើយនេះជាកំណើនដំបូងបង្អស់ក្នុងកំណត់ត្រាស្រាវជ្រាវចាប់តាំងពីជាង ២០ ឆ្នាំមុនមកម្ល៉េះ។

ការល្បាតប្រកបដោយប្រសិទ្ធិភាពតាមទន្លេដោយក្រុមឆ្មាំទន្លេ និងការរឹបអូសមងនេសាទខុសច្បាប់ដែលទាក់ជាប់ និងធ្វើឱ្យសត្វផ្សោតលង់ទឹកស្លាប់ដោយចៃដន្យ ជាហេតុផលចម្បងក្នុងការធ្វើឱ្យមានកំណើនជាប្រវិត្តសាស្ត្រនេះ។ ក្នុងអំឡុងពេលជាងពីរឆ្នាំមុន មងនេសាទខុសច្បាប់ប្រវែងសរុប ៣៥៨ គ.ម. ត្រូវបានចាប់រឹបអូសចេញពីតំបន់ជម្រកស្នូលរបស់សត្វផ្សោត។ មងនេសាទខុសច្បាស់ដែលត្រូវបានរឹបអូសនេះមានប្រវែងស្ទើតែស្មើរនឹងចំនួនទ្វេដងនៃប្រវែងខ្សែទឹកទន្លេដែលជាជម្រករបស់សត្វផ្សោតរស់នៅ។

"បន្ទាប់ពីការព្យាយាមអស់រយៈពេលរាប់ឆ្នាំ ជាចុងក្រោយយើងអាចជឿបានថាសត្វផ្សោតដែលជាសត្វនិមិត្តរូបទាំងនេះ អាចត្រូវបានការពារឱ្យផុតពីការវិនាសផុតពូជបាន ដោយសារតែកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងរដ្ឋាភិបាល អង្គការ WWF វិស័យទេសចរណ៍ និងសហគមន៍មូលដ្ឋាន" ប្រសាសន៍លោក សេង ទៀក នាយក នៃអង្គការ WWF-កម្ពុជា។ "អ្នកបើកទូកទេសចរណ៍ ជាធាតុផ្សំសម្ខាត់ក្នុងរឿងជោគជ័យមួយនេះ ព្រោះពួកគាត់ធ្វើការយ៉ាងជិតស្និទជាមួយកិច្ចការពង្រឹងច្បាប់ ក្នុងការរាយការណ៍អំពីការនេសាទខុសច្បាប់ និងជួយក្នុងការរឹបអូសយកមងនេសាទខុសច្បាប់។"

ការសិក្សាស្រាវជ្រាវជាផ្លូវការដំបូងបង្អស់ក្នុងឆ្នាំ១៩៩៧ បានធ្វើការប៉ាន់ប្រមាណថាមានចំនួនសត្វផ្សោតទន្លេមេគង្គប្រហែល ២០០ ក្បាល ក្នុងទន្លេមេគង្គ ហើយចំនួននេះបានធ្លាក់ចុះជាបន្តបន្ទាប់ដោយសារការជាប់មង និងបាត់បង់ជម្រក រហូតធ្លាក់មកសល់ត្រឹមចំនួន ៨០ ក្បាល ក្នុងឆ្នាំ២០១៥។ ប៉ុន្តែឥឡូវនេះ ការធ្លាក់ចុះនេះទំនងជាមានការប្រសើរឡើងវិញ។

ជាមួយនឹងកំណើន ១០% នៃសត្វផ្សោតទន្លេមេគង្គ ការសិក្សាស្រាវជ្រាវនេះ ក៏បានចង្អុលបង្ហាញអំពីកត្តាដែលធានាឱ្យមាននូវភាពរស់រានមានជីវិតរយៈពេលវែងរបស់សត្វផ្សោត ដោយមានភាពប្រសើរឡើងនូវអត្រារស់រានមានជី

វិតរបស់សត្វផ្សោតពេញវ័យ កំណើននៃចំនួនកូនផ្សោត និងការថយចុះនៃអត្រាស្លាប់សរុប។ សត្វផ្សោត ០២ ក្បាល បានស្លាប់ក្នុងឆ្នាំ២០១៧ និងស្លាប់ ០៩ ក្បាល ក្នុងឆ្នាំ២០១៥ ខណៈដែលមានសត្វផ្សោតកើតថ្មីចំនួន ០៩ ក្បាល ធ្វើឱ្យចំនួនសត្វផ្សោតដែលកើតក្នុងអំឡុងពេល ០៣ ឆ្នាំចុងក្រោយ កើនបានចំនួន ៣២ ក្បាល។

"ផ្សោតទន្លេមេគង្គជាសូចនាករ នៃសុខភាពរបស់ទន្លេមេគង្គ ហើយការស្តារឡើងវិញនូវចំនួនសត្វផ្សោត ជាសញ្ញាដ៏មានសង្ឃឹមមួយចំពោះទន្លេមេគង្គ និងប្រជាពលរដ្ឋរាប់លាននាក់ដែលពឹងអាស្រ័យលើទន្លេមេគង្គ។ ពួកយើងអបអរចំពោះព័ត៌មានដ៏ល្អនេះ ប៉ុន្តែឥឡូវនេះមិនទាន់ជាពេលដើម្បីសប្បាយរីករាយនៅឡើយទេ។ ដរាបណាការគំរាមកំហែងលើអាយុជីវិតរបស់សត្វផ្សោតនៅតែមាន យើងត្រូវតែបង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដង ក្នុងការការពារសត្វផ្សោត សម្រាប់ទាំងអនាគតរបស់វា និងសម្រាប់ទាំងទន្លេ និងសហគមន៍នានាដែលរស់នៅតាមបណ្តោយទន្លេ។" ប្រសាសន៍បន្ថែមរបស់លោក សេង ទៀក។

"សត្វផ្សោតទន្លេមេគង្គត្រូវបានចាត់ទុកជារតនសម្បត្តិជាតិមានជីវិតរបស់ប្រទេសកម្ពុជា ហើយលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ ឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ពួកយើងអស់រយៈពេលជាច្រើនឆ្នាំ ក្នុងការការពារប្រភេទសត្វមួយនេះ។ ពួកយើងនឹងបន្តកិច្ចខិតខំប្រឹងប្រែងអភិរក្សនេះ ដើម្បីស្តារចំនួនសត្វផ្សោតឡើងវិញ ដោយលុបបំបាត់រាល់ការគំរាមកំហែងនានាចំពោះភាពរស់រានមានជីវិតរបស់សត្វផ្សោត។" ប្រសាសន៍របស់ឯកឧត្តម អេង ជាសាន ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាប្រធាននាយកដ្ឋានជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការសិក្សាស្រាវជ្រាវត្រូវបានធ្វើឡើងតាមបណ្តោយខ្សែទឹកទន្លេមេគង្គចម្ងាយ ១៩០ គ.ម. ចាប់ពីទីរួមខេត្តក្រចេះ នៃប្រទេសកម្ពុជា ទៅដល់ល្បាក់ទឹកខោន ព្រំប្រទល់ប្រទេសឡាវ។ ការសិក្សាស្រាវជ្រាវនេះត្រូវបានធ្វើឡើងតាមបណ្តោយខ្សែទឹកទាំងទៅទាំងមក ដោយមានក្រុមអ្នកស្រាវជ្រាវថតរូបសត្វផ្សោតយកមកប្រៀបធៀបដើម្បីពិនិត្យមើលសញ្ញាសម្គាល់លើខ្នង និងព្រុយខ្នងរបស់វា ទៅនឹងទិន្នន័យនៃសត្វផ្សោតដែលបានកំណត់សម្គាល់រួចហើយ។

###

## កំណត់ចំណាំ ចំពោះនាយកនិពន្ធ៖

រូបភាពកូនសត្វផ្សោតមាននៅទីនេះ៖
https://www.dropbox.com/sh/4vhf2fnyk4ynthr/AABIGCciGgVgT393r4OiMJmPa?dl=0

## សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

លោក អ៊ុន ចក្រី ប្រធានទំនាក់ទំនងព័ត៌មាន នៃអង្គការ WWF-កម្ពុជា
+855 17 234 555
un.chakrey@wwfgreatermekong.org

## អំពីអង្គការ WWF-កម្ពុជា

អង្គការ WWF បានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩៨ ដែលជាផ្នែកមួយនៃអង្គការ WWF ក្នុងមហាតំបន់ទន្លេមេគង្គ។ បេសកកម្មរបស់អង្គការ WWF គឺធានាឱ្យមានការចូលរួមគាំទ្រពីមនុស្សគ្រប់រូបដើម្បីធ្វើការអភិរក្សនូវជីវចម្រុះដ៏សម្បូរបែបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អង្គការ WWF-កម្ពុជា នឹងជម្រុញឱ្យមានឱកាសថ្មីៗជាច្រើនដែលផ្តល់ផលប្រយោជន៍ដល់មនុស្ស និងធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ព្រមទាំងចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកទឹកចិត្តឱ្យមានការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ សម្រាប់ព័ត៌មានលំអិតសូមចូលទៅកាន់គេហទំព័ររបស់អង្គការ WWF-កម្ពុជា៖

www.cambodia.panda.org